# 26 밥을 먹은 후에 이 약을 드세요

## បន្ទាប់ពីញ៉ាំបាយរួច សូមពិសាថ្នាំនេះ

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការនិយាយអំពីលំដាប់លំដោយ, ការហាម |
| □ វេយ្យាករណ៍ | -(으)ㄴ 후에, -지 마세요 |
| □ ពាក្យថ្មី | សរីរាង្គ, រោគសញ្ញា |
| □ ព័ត៌មាន · វប្បធម៌ | ថ្នាំសង្គ្រោះបន្ទាន់នៅផ្ទះ |

## 대화 1 ការសន្ទនា ១

Track 82



តើហេតុអ្វីបានជាបារូទៅឱសថស្ថាន? ដំបូងសូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន បន្ទាប់មកសូមថាតាម។

약사 어떻게 오셨어요? តើអញ្ជើញមកមានការអ្វីដែរ?

바루 머리가 아파서 왔어요.
ខ្ញុំមកទីនេះ ដោយសារតែខ្ញុំឈឺក្បាល។

약사 언제부터 아프셨어요?
តើអ្នកឈឺតាំងពីពេលណា?

바루 어젯밤부터요.
어제 저녁에 회식이 있어서 술을 좀 마셨어요.
គឺតាំងពីយប់ម្សិលមិញ។
ដោយសារតែម្សិលមិញ មានកម្មវិធីទៅញ៉ាំអីជាមួយខាងក្រុមហ៊ុន ខ្ញុំបានញ៉ាំស្រាបន្តិច។

약사 아, 술 때문에 그런 것 같네요.
밥을 먹은 후에 이 약을 드세요.
អូ...បើអញ្ចឹងប្រហែលដោយសារតែស្រាហើយ។
បន្ទាប់ពីញ៉ាំបាយរួច សូមពិសាថ្នាំនេះ។

바루 네, 감사합니다. បាទ, អរគុណ។

**부터**
ប្រើប្រាស់នៅខាងក្រោយនាមពេលវេលា ដើម្បីបញ្ជាក់អំពីចំណុចចាប់ផ្តើមនៃរឿងហេតុអ្វីមួយ។
- 아침부터 배가 아파요.
  ឈឺពោះ តាំងពីព្រឹក។
- 내일부터 다른 공장에서 일해요.
  ចាប់ពីថ្ងៃស្អែកទៅ ខ្ញុំធ្វើការនៅឯរោងចក្រផ្សេង។

**때문에**
ប្រើប្រាស់ដើម្បីបញ្ជាក់ប្រាប់ថានាមខាងមុខគឺជាដើមហេតុនៃរឿងហេតុខាងក្រោយ។
- 비 때문에 길이 복잡해요.
  ដោយសារតែភ្លៀង ទើបផ្លូវញ៉េវញ៉ៃ។
- 일 때문에 바빠요.
  ដោយសារតែការងារ ទើបរវល់។



តើអ្នកបានស្តាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? អញ្ចឹងសូមសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 바루 씨는 왜 약국에 갔어요? តើហេតុអ្វីបានជាបារូទៅឱសថស្ថាន?
2. 바루 씨는 언제부터 아팠어요? តើបារូឈឺចាប់តាំងពីពេលណា?

정답 1. 머리가 아파서 갔어요. 2. 어젯밤부터 아팠어요.

## 어휘 1 ពាក្យថ្មី ១ | 신체 សរីរាង្គ

តោះ! យើងមើលពាក្យដែលពាក់ព័ន្ធទៅនឹងសរីរាង្គនីមួយៗរបស់យើងទាំងអស់គ្នា។







សូមកុំមើលពាក្យខាងលើ ហើយដោះស្រាយសំណួរខាងក្រោម។

1. 그림에 맞는 표현을 〈보기〉에서 골라 넣으세요.
សូមជ្រើសរើសកន្សោមពាក្យពី<ឧទាហរណ៍>មកបំពេញឲ្យបានត្រឹមត្រូវទៅនឹងរូបភាព។

**보기**
머리
눈
코
배
귀
다리
팔
어깨
목
발




정답 1) 머리 2) 눈 3) 코 4) 귀 5) 목 6) 어깨 7) 팔 8) 배 9) 다리 10) 발

## 문법 1 វេយ្យាករណ៍ ១ | -(으)ㄴ 후에

G26-1

យើងប្រើប្រាស់ '-(으) ㄴ후' ភ្ជាប់បានជាមួយតែកិរិយាស័ព្ទប៉ុណ្ណោះ ដើម្បីបញ្ជាក់ន័យថា "បន្ទាប់ពីរឿងអ្វីមួយបញ្ចប់រួច"។

| 자음(ព្យញ្ជនៈ) → **-은 후에** | 모음(ស្រៈ), 자음 'ㄹ'(ព្យញ្ជនៈ 'ㄹ') → **-ㄴ 후에** |
|---|---|
| 먹다 → 먹**은 후에** | 보다 → **본 후에**<br>만들다 → 만**든 후에** |

- 가: 언제 영화 보러 갈 거예요? តើអ្នកនឹងទៅមើលភាពយន្ត នៅពេលណា?
  나: 일이 **끝난 후에** 가려고 해요. ខ្ញុំរកទៅ បន្ទាប់ពីហើយការងារ។
- 가: 이 약은 언제 먹어야 돼요? តើថ្នាំនេះ ត្រូវញ៉ាំនៅពេលណា?
  나: 밥을 **먹은 후에** 드세요. សូមពិសា ក្រោយញ៉ាំបាយរួច។

'후에' ពេលខ្លះក៏ត្រូវបានប្រើដោយភ្ជាប់ជាមួយនាមនៅក្នុងទម្រង់៖ 'នាម + 후에' ផងដែរ។

- **식사 후에** 다시 회의를 하겠습니다. ក្រោយពិសាអាហាររួច នឹងចាប់ផ្តើមធ្វើការប្រជុំម្តងទៀត។
- **퇴근 후에** 뭐 할 거예요? ក្រោយចេញពីធ្វើការ តើអ្នកនឹងធ្វើអ្វី?

### 크메르어와 한국어의 공통점과 차이점 ចំណុចដូចគ្នានិងខុសគ្នារវាងភាសាខ្មែរនិងភាសាកូរ៉េ

នៅក្នុងភាសាខ្មែរ នៅពេលដែលប្រយោគខាងមុខ និងប្រយោគខាងក្រោយមានទំនាក់ទំនងគ្នាទៅវិញទៅមកជាកាលវេលា គឺយើងប្រើប្រាស់ "ហើយ(និង)"។ ក៏ប៉ុន្តែនៅក្នុងភាសាកូរ៉េវិញ គឺគេធ្វើការភ្ជាប់ពាក្យបន្ថែមចុង '-(으)ㄴ 후에' ជាប់នឹងកិរិយាស័ព្ទដើមនៃប្រយោគខាងមុខ ដើម្បីរៀបរាប់ពីលំដាប់លំដោយនៃកាលវេលារបស់សកម្មភាពអ្វីមួយ។

- 밥을 **먹은 후에** 약을 먹어요. ផឹកថ្នាំ បន្ទាប់ពីហូបបាយរួច។
- 사람들이 다 **모인 후에** 출발했어요. បានចេញដំណើរ បន្ទាប់ពីមនុស្សទាំងអស់បានមកជុំគ្នា។



តើអ្នកយល់ពីការប្រើប្រាស់ '-(으)ㄴ 후에' ហើយមែនដែរឬទេ? សូមធ្វើការជ្រើសរើសចម្លើយដែលត្រឹមត្រូវមកបញ្ចប់ការសន្ទនា។

2. 대화에 맞는 대답을 고르세요. សូមអានការសន្ទនា បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

1) 쇼핑하다 → 영화를 보다

가: 우리 주말에 뭐 할까요? តើថ្ងៃចុងសប្តាហ៍ ពួកយើងធ្វើអ្វីល្អ?
나: ________________.

① 쇼핑을 한 후에 영화를 봐요
② 영화를 본 후에 쇼핑을 해요

2) 밥을 먹다 → 약을 먹다

가: 이 약은 어떻게 먹어야 돼요? តើថ្នាំនេះ ត្រូវញ៉ាំយ៉ាងម៉េច?
나: ________________.

① 밥을 먹은 후에 약을 드세요
② 약을 먹은 후에 밥을 드세요

정답 1) ① 2) ①

## 대화 2 ការសន្ទនា ២

Track 83



ម៉ូនីខាបានទៅឱសថស្ថាន។ តើហេតុអ្វីបានជានាងទៅឱសថស្ថាន? ដំបូងសូមស្ដាប់ការសន្ទនាឲ្យបាន ២ដងជាមុនសិន រួចចូរថាតាម។

**약 사** 어디가 불편하세요?
តើអ្នកមិនស្រួលត្រង់ណាដែរ?

**모니카** 오늘 아침부터 배가 아프고 설사를 해요.
ថ្ងៃនេះខ្ញុំឈឺពោះ និងរាគតាំងពីព្រឹក។

**약 사** 아침에 **뭘** 드셨어요?
តើអ្នកបានពិសាអ្វី កាលពីព្រឹក?

**모니카** 빵하고 우유를 먹었는데 우유 맛이 좀 이상했어요.
ខ្ញុំបានញ៉ាំនំប៉័ង និងទឹកដោះគោ តែរសជាតិទឹកដោះ ដូចជារាងចម្លែកបន្តិចដែរ។

**약 사** 그럼 이 약을 드세요. **그리고** 오늘은 유제품은 **먹지 마세요**.
បើអញ្ចឹង សូមពិសាថ្នាំនេះ។ ហើយសូមកុំបរិភោគ ផលិតផលចម្រាញ់ចេញពីទឹកដោះគោនៅក្នុងថ្ងៃនេះអី។

**모니카** 네, 알겠습니다.
ចាស, ខ្ញុំយល់ហើយ។

> **뭘** អ្វី
> 뭐+를=뭐를=뭘
> · 주말에 뭘 했어요?
> តើថ្ងៃចុងសប្ដាហ៍អ្នកបានធ្វើអ្វី?
> · 뭘 먹고 싶어요?
> តើអ្នកចង់ញ៉ាំអ្វី?

> **그리고** ហើយ
> ប្រើប្រាស់ដើម្បីភ្ជាប់ប្រយោគជាមួយនឹងប្រយោគហើយប្រយោគទាំង២មានន័យស្របគ្នា។
> · 저는 빵을 좋아해요.
> 그리고 라면도 좋아해요.
> ខ្ញុំចូលចិត្តនំប៉័ង។ ហើយខ្ញុំក៏ចូលចិត្តមីដែរ។



តើអ្នកបានស្ដាប់និងថាតាមការសន្ទនារួចហើយមែនដែរឬទេ? បើអញ្ចឹងសូមសាកល្បងឆ្លើយសំណួរខាងក្រោម។

1. 모니카 씨는 아침에 뭘 먹었어요? តើម៉ូនីខាបានញ៉ាំអ្វីកាលពីព្រឹក?
2. 모니카 씨는 언제부터 배가 아팠어요? តើម៉ូនីខាឈឺពោះតាំងពីពេលណា?

정답 1. 빵하고 우유를 먹었어요. 2. 아침부터 배가 아팠어요.

## 어휘 2 ពាក្យថ្មី ២ | 증상 រោគសញ្ញា



តោះ! យើងមើលពាក្យដែលពាក់ព័ន្ធទៅនឹងរោគសញ្ញាទាំងអស់គ្នា។



감기에 걸리다
ផ្តាសាយ



열이 나다
ក្តៅខ្លួន



기침을 하다
ក្អក



콧물이 나다
ហៀរសំបោរ



배탈이 나다
ឈឺពោះ(មិនស្រួលពោះ)



설사를 하다
រាគ



소화가 안 되다
ពិបាករំលាយអាហារ
(ក្រពះមិនស្រួល)



토하다
ក្អួត



손을 베다
មុតដៃ



손을 데다
រលាកដៃ



발목을 삐다
គ្រេច កជើង



다리가 부러지다
បាក់ជើង



តោះ! សូមរំលឹកពីពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកសាកល្បងដោះស្រាយសំណួរ។

1. 그림을 보고 알맞은 말을 연결하세요. សូមមើលរូបភាព បន្ទាប់មកចូរភ្ជាប់ទៅនឹងពាក្យដែលត្រឹមត្រូវ។

① 

② 

③ 

④ 

⑤ 

㉠ 소화가 안 되다 ㉡ 손을 데다 ㉢ 기침을 하다 ㉣ 열이 나다 ㉤ 발목을 삐다

정답 ① ㉡ ② ㉣ ③ ㉠ ④ ㉤ ⑤ ㉢

## 문법 2 វេយ្យាករណ៍ ២ | –지 마세요

G26-2

យើងប្រើប្រាស់ '–지 마세요' ភ្ជាប់បានជាមួយតែកិរិយាស័ព្ទប៉ុណ្ណោះ ដើម្បីធ្វើការស្នើសុំឬបញ្ជាក្នុងន័យហាមប្រាមមិនឲ្យធ្វើអ្វីមួយ។

- 가: 열이 많이 나니까 오늘은 밖에 **나가지 마세요.** ដោយសារតែអ្នកឡើងកម្តៅខ្លាំង ដូច្នេះថ្ងៃនេះ សូមកុំចេញទៅខាងក្រៅ។
  나: 네, 알겠습니다. បាទ/ចាស, ខ្ញុំដឹងហើយ។
- 가: 소화가 안 되고 계속 토해요. ពិបាករំលាយអាហារ ហើយក្អួតរហូត។
  나: 이 약을 드세요. 그리고 오늘은 밥을 **먹지 마세요.** សូមពិសាថ្នាំនេះ។ ហើយថ្ងៃនេះ សូមកុំញ៉ាំបាយ។



តើអ្នកយល់ពី '–지 마세요' ហើយឬនៅ? សូមជ្រើសរើសចម្លើយដែលត្រឹមត្រូវ ហើយសាកល្បងបំពេញការសន្ទនាខាងក្រោម។

2. 대화를 읽고 맞는 대답을 고르세요. សូមអានការសន្ទនា ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

1) 가: 발목을 삐었어요. គ្រេច កជើង។
   나: ______________________.

   ① 많이 걷지 마세요　　② 밥을 먹지 마세요

2) 가: 열이 나고 콧물이 많이 나요. ក្តៅខ្លួន និងហៀរសំបោរខ្លាំង។
   나: ______________________.

   ① 오늘은 밖에 나가지 마세요　　② 오늘은 기침을 하지 마세요

정답 1) ① 2) ①



រៀនថែមបន្តិចទៀតតើល្អដែរឬទេ? សូមសាកល្បងប្រើប្រាស់ '–지 마세요' មកបញ្ចប់ការសន្ទនា។

1) 가: 빵하고 우유를 먹었는데 배가 아파요.
   나: 이 약을 드세요. 그리고 오늘은 우유를 ______________________.

2) 가: 출퇴근 시간에는 택시비가 너무 많이 나와요.
   나: 맞아요. 출퇴근 시간에는 택시를 ______________________.

정답 1) 드시지 마세요 2) 타지 마세요

## 활동 សកម្មភាព

약국에서 〈보기〉처럼 이야기해 보세요. សូមសាកល្បងនិយាយដូចទៅនឹង<ឧទាហរណ៍>នៅឱសថស្ថាន។

보기



열이 많이 나다 ក្តៅខ្លួនខ្លាំង

밖에 나가다
ចេញទៅខាងក្រៅ

환자: 열이 많이 나요.
ក្តៅខ្លួនខ្លាំង។

약사: 밥을 먹은 후에 이 약을 드세요.
그리고 오늘은 밖에 나가지 마세요.
ក្រោយពីញ៉ាំបាយរួច សូមពិសាថ្នាំនេះ។
ហើយថ្ងៃនេះ សូមកុំចេញទៅខាងក្រៅ។

1)



계속 토하다 ក្អួតរហូត

밥을 먹다
ញ៉ាំបាយ
✕

2)



손을 데었다 រលាកដៃ

요리를 하다
ចម្អិនម្ហូប
✕

3)



계속 설사를 하다 រាគរហូត

아이스크림을 먹다
ញ៉ាំការ៉េម
✕

4)



발목을 삐었다 គ្រេច កជើង

많이 걷다
ដើរច្រើន
✕

정답 1) 환자: 계속 토해요.
약사: 밥을 먹은 후에 이 약을 드세요. 그리고 오늘은 밥을 먹지 마세요.

2) 환자: 손을 데었어요.
약사: 밥을 먹은 후에 이 약을 드세요. 그리고 오늘은 요리를 하지 마세요.

3) 환자: 계속 설사를 해요.
약사: 밥을 먹은 후에 이 약을 드세요. 그리고 오늘은 아이스크림을 먹지 마세요.

4) 환자: 발목을 삐었어요.
약사: 밥을 먹은 후에 이 약을 드세요. 그리고 오늘은 많이 걷지 마세요.

## 정보 ព័ត៌មាន

# 가정 비상약

ថ្នាំសង្គ្រោះបន្ទាន់នៅផ្ទះ

### ✚구급함 ឧបករណ៍សង្គ្រោះបឋម




### ✚약국이 문을 닫으면? ប្រសិនបើឱសថស្ថានបិទទ្វារ?

늦은 밤이나 공휴일에 갑자기 약을 사야 하는데 약국이 문을 닫았으면 편의점에서도 가정 비상약을 살 수 있습니다. 편의점에는 감기약, 소화제, 진통제, 해열제, 파스, 연고와 같은 약이 있습니다.

ប្រសិនបើនៅកណ្ដាលអាធ្រាត ឬក៏ថ្ងៃបុណ្យឈប់សម្រាក ប៉ុន្តែអ្នកស្រាប់តែត្រូវការទិញថ្នាំ ហើយបើសិនជាឱសថស្ថានបិទទ្វារទៀតនោះ អ្នកអាចរកទិញថ្នាំសង្គ្រោះបន្ទាន់នៅឯម៉ាត២៤ម៉ោងបាន។ នៅម៉ាត២៤ម៉ោង គឺមានថ្នាំផ្សេងៗជាច្រើនដូចជា៖ ថ្នាំផ្ដាសាយ ថ្នាំរំលាយអាហារ ថ្នាំបំបាត់ការឈឺចាប់ ថ្នាំបញ្ចុះកម្ដៅ កៅអៀក ថ្នាំលាបជាដើម។



감기약
ថ្នាំផ្ដាសាយ



소화제
ថ្នាំរំលាយអាហារ



진통제
ថ្នាំបំបាត់ការឈឺចាប់



해열제
ថ្នាំបញ្ចុះកម្ដៅ

# EPS-TOPIK 듣기 វិញ្ញាសាស្តាប់ EPS-TOPIK



ចាប់ពីសំណួរទី១ ដល់សំណួរទី៣ គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។ មុននឹងស្តាប់ សូមសាកល្បងក្រឡេកមើលខ្លឹមសារនៃសំណួរជាមុនសិន។

[1~3] 다음 그림을 보고 알맞은 대답을 고르십시오.
សូមមើលរូបភាព ហើយធ្វើការជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

Track 84

1. 

이 사람은 어디가 아픕니까? តើមនុស្សម្នាក់នេះ ឈឺអ្វីដែរ?

① ② ③ ④

2. 

이 사람의 증상은 어떻습니까? តើរោគសញ្ញារបស់មនុស្សម្នាក់នេះ យ៉ាងម៉េចដែរ?

① ② ③ ④

3. 

이 사람은 어디를 다쳤습니까? តើមនុស្សម្នាក់នេះ របួសកន្លែងណា?

① ② ③ ④



សំណួរបន្ទាប់ គឺជាការជ្រើសរើសចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។
មុននឹងស្តាប់សំណួរ សូមសាកល្បងក្រឡេកមើលខ្លឹមសារនៃចម្លើយជាមុនសិន។

[4~5] 하나의 이야기를 듣고 두 개의 질문에 대답하십시오.
សូមស្តាប់ការនិយាយតែមួយគត់ បន្ទាប់មកចូរឆ្លើយទៅនឹងសំណួរទាំង ២។

4. 여기는 어디입니까? តើទីនេះគឺជាកន្លែងអ្វី?
① 약국 ② 식당
③ 은행 ④ 백화점

5. 남자는 어디가 아픕니까? តើបុរសម្នាក់នេះឈឺអ្វីដែរ?
① 콧물이 많이 납니다. ② 머리가 아프고 열이 납니다.
③ 아침부터 소화가 안 됩니다. ④ 밥을 먹은 후에 설사를 했습니다.



### 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្តាប់

1. ① 남: 팔이 아픕니다. ឈឺដៃ។
   ② 남: 이가 아픕니다. ឈឺធ្មេញ។
   ③ 남: 머리가 아픕니다. ឈឺក្បាល។
   ④ 남: 다리가 아픕니다. ឈឺជើង។
2. ① 여: 토를 합니다. ក្អួត។
   ② 여: 콧물이 납니다. ហៀរសំបោរ។
   ③ 여: 기침을 합니다. ក្អក។
   ④ 여: 설사를 합니다. រាគ។
3. ① 남: 손을 데었습니다. រលាកដៃ។
   ② 남: 손을 베었습니다. មុតដៃ។
   ③ 남: 발목을 삐었습니다. គ្រេច កជើង។
   ④ 남: 다리가 부러졌습니다. បាក់ជើង។

4-5. 여: 어서 오세요. 어떻게 오셨어요? សូមស្វាគមន៍! តើអញ្ជើញមកមានការអ្វីដែរ?
남: 열이 나고 머리가 아파요. ក្តៅខ្លួន ហើយនិងឈឺក្បាល។
여: 언제부터 열이 났어요? តើអ្នកក្តៅខ្លួនចាប់តាំងពីពេលណាដែរ?
남: 아침부터 그랬어요. តាំងពីព្រឹកមក។
여: 여기 약을 드릴게요. 밥을 먹은 후에 드세요. ចាំខ្ញុំឲ្យថ្នាំទៅផឹក។ ក្រោយបាយរួច សូមពិសាថ្នាំ។
남: 네, 알겠습니다. បាទ, ខ្ញុំដឹងហើយ។

**정답** 1. ② 2. ② 3. ① 4. ① 5. ②

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-26

[1~2] 질문을 듣고 알맞은 대답을 고르십시오. សូមស្តាប់សំណួរ បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

1. ① 배가 많이 아파요.
   ② 오후에 병원에 가야 해요.
   ③ 어제 약국에서 약을 샀어요.
   ④ 차가운 음식을 많이 먹었어요.

2. ① 식사 후에 드세요.
   ② 약을 먹은 후에 드세요.
   ③ 오늘은 밖에 나가지 마세요.
   ④ 당분간 술은 마시지 마세요.

### 확장 연습 듣기 대본 អត្ថបទស្តាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: 건우 씨, 왜 배탈이 났어요? ខន់អ៊ូ, ហេតុអ្វីមិនស្រួលពោះ?
2. 남: 이 약은 언제 먹어야 돼요? តើថ្នាំនេះត្រូវញ៉ាំនៅពេលណាដែរ?

**정답** 1. ④ 2. ①

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK



ចាប់ពីសំណួរទី១ដល់ទី៣ គឺជាការអានអត្ថបទសន្ទនា ហើយជ្រើសរើសកន្សោមពាក្យដែលត្រឹមត្រូវដើម្បីបំពេញចន្លោះ។ សូមរំលឹកពីពាក្យ ឬកន្សោមពាក្យដែលបានរៀននៅខាងមុខរួចមកហើយនោះបណ្ដើរ និងសាកល្បងដោះស្រាយសំណួរបណ្ដើរ។

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1.
가: 리리 씨, 얼굴이 많이 안 좋아요. លីលី, ទឹកមុខដូចជាមិនសូវល្អសោះ។
나: __________에 걸렸어요. 목도 아프고 열도 나요. ខ្ញុំផ្ដាសាយ។ ក ក៏ឈឺ ហើយក៏ក្ដៅខ្លួនដែរ។

① 콧물 ② 기침 ③ 감기 ④ 배탈

2.
가: 리한 씨, 제가 손을 베었는데 혹시 __________ 있어요? រីហាន់, ខ្ញុំមុតដៃ តើមានថ្នាំលាបដែរទេ?
나: 네, 잠깐만 기다리세요. បាទ, សូមរង់ចាំបន្តិច។

① 파스 ② 연고 ③ 소화제 ④ 해열제

3.
가: ______________________________? តើអ្នកមិនស្រួលត្រង់ណាដែរ?
나: 아침부터 계속 설사를 해요. ខ្ញុំរាគរូស តាំងពីព្រឹក។

① 누가 아파요 ② 어디가 아프세요
③ 약국이 어디에 있어요 ④ 이 약은 어떻게 먹어야 돼요



សំណួរទី៤ គឺជាចង់ថ្នាំ ចំណែកឯសំណួរទី៥វិញ គឺជាសារ។ សូមរំលឹកពីពាក្យនិងវេយ្យាករណ៍ដែលបានរៀនរួចមកហើយនោះបណ្ដើរ និងសាកល្បងដោះស្រាយសំណួរបណ្ដើរ។

[4~5] 다음 질문에 답하십시오. ចូរឆ្លើយសំណួរខាងក្រោម។

내복약 ថ្នាំលេប
김 지 수 님
កញ្ញា គីមជីស៊ូ
용법 : វិធីសាស្ត្រប្រើប្រាស់
하루 3 회 2일분
មួយថ្ងៃ ៣ដង សម្រាប់២ថ្ងៃ
매 식후 30 분 복용
ញ៉ាំរៀងរាល់ក្រោយបាយរួច ៣០នាទី
1 회 1 포씩 복용
ញ៉ាំម្ដង ១កញ្ចប់
2014 년 6 월 12일
ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤

4. 김지수 씨는 하루에 약을 몇 번 먹어야 합니까?
តើកញ្ញា គីមជីស៊ូ ត្រូវញ៉ាំថ្នាំប៉ុន្មានដងក្នុងមួយថ្ងៃ?
① 한 번
② 두 번
③ 세 번
④ 네 번

5. 읽은 내용과 같은 것을 고르십시오.
ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវទៅនឹងអត្ថបទ។

반장님, 모니카예요. 오늘 너무 아파서 회사에 못 갑니다. 어제 저녁부터 배가 아프고 계속 설사를 했어요. 어제 약국에서 약을 사 먹었는데 아직도 아파요. 오늘 아침에는 열도 나서 오늘은 쉬려고 해요. 죄송합니다.
លោកប្រធាន, ខ្ញុំគឺម៉ូនីខា។ ដោយសារតែថ្ងៃនេះ ខ្ញុំមិនស្រួលខ្លួនខ្លាំង ខ្ញុំមិនបានទៅក្រុមហ៊ុនទេ។ ខ្ញុំឈឺពោះ និងរាគរូស តាំងពីម្សិលមិញ។ ម្សិលមិញខ្ញុំបានទៅឱសថស្ថានទិញថ្នាំដែរ តែនៅតែឈឺ។ ហើយព្រឹកនេះ ខ្ញុំក្ដៅខ្លួនទៀត ទើបខ្ញុំចង់សម្រាកថ្ងៃនេះ។ សូមអភ័យទោសផង។

① 모니카 씨는 지금 아프지 않습니다. ② 모니카 씨는 오늘 회사에 갈 것입니다.
③ 모니카 씨는 어제 약국에 못 갔습니다. ④ 모니카 씨는 어제 저녁부터 배가 아팠습니다.



정답 1. ③ 2. ② 3. ② 4. ③ 5. ④



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오. ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1. 발목을 삐었을 때는 많이 걷지 말고 앉아서 쉬어야 합니다. ____________ 찜질을 해 주는 것이 좋습니다.

នៅពេលដែលអ្នកគ្រេច កជើង អ្នកមិនត្រូវដើរ ហើយត្រូវអង្គុយសម្រាក។ ហើយការរកអ្វីយកមកស្អំក៏ល្អដែរ។

① 그러나 ② 그리고 ③ 그래서 ④ 그러면

2. 건우 씨가 계단에서 ____________ 다리를 다쳤습니다. 그래서 병원에 가서 치료를 받았습니다.

លោក ខន់អ៊ូ ដោយសារតែគាត់ដួលនៅឯជណ្តើរ គាត់ក៏របួសជើង។ ដូច្នេះហើយ គាត់បានទៅមន្ទីរពេទ្យទទួលការព្យាបាល។

① 돌아가서 ② 먹어봐서 ③ 시작해서 ④ 넘어져서

3. 식사를 준비하다가 칼에 손을 ________________. 다행히 피가 많이 나지 않아서 밴드를 붙였습니다.

ពេលរៀបចំចម្អិនម្ហូបញ៉ាំ ក៏មុតដៃ។ សំណាងហើយ ដែលមិនចេញឈាមច្រើន ខ្ញុំក៏បានបិទបង់បិទរបួស។

① 걸렸습니다 ② 데었습니다 ③ 베었습니다 ④ 토했습니다

4. 다음 글을 읽고 무엇에 대한 글인지 고르십시오.
សូមអានអត្ថបទ បន្ទាប់មកចូរជ្រើសរើសថា តើអត្ថបទនេះ និយាយអំពីអ្វី។

오래 되었거나 상한 음식을 먹으면 배탈이 나기 쉽습니다. 배탈에는 여러 가지 증상이 있는데 배가 아프고 설사를 하기도 합니다. 심하면 토하거나 머리가 아플 때도 있습니다.

បើសិនជាញ៉ាំម្ហូបដែលទុកយូរ ឬក៏ម្ហូបដែលផ្អូម អាចឲ្យយើងងាយនឹងឈឺពោះណាស់។ អាការៈឈឺពោះគឺមានច្រើនប្រភេទ ក្នុងនោះក៏មានអាការៈដូចជាឈឺពោះ និងរាគផងដែរ។ បើធ្ងន់វិញ គឺអាចដល់ថ្នាក់ក្អួត ឬក៏ឈឺក្បាលជាដើម។

① 감기 예방 ② 두통 치료
③ 배탈 증상 ④ 소화 불량

정답 1. ② 2. ④ 3. ③ 4. ③